ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២៤៦៣ ព.ណ.ន.ចបព

ថ្ងៃសុក្រ ១១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី ការបន្តលើកលែងការពិន័យចំពោះក្រុមហ៊ុនខកខានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ តាមរយៈការពិន័យត្រឹម ១ ឆ្នាំចុងក្រោយ សម្រាប់រយៈពេល ៦ ខែ

សូមជម្រាបជូនថា ក្រសួងពាណិជ្ជកម្ម ទទួលបានសំណូមពរជាបន្តបន្ទាប់ និងសង្កេតឃើញពីភាពចាំបាច់របស់ក្រុមហ៊ុន ដែលមានបំណងបំពេញកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ប៉ុន្តែមានការខកខានមកបំពេញមិនទាន់កាលបរិច្ឆេទ ដូចដែលបានធ្វើការជូនដំណឹងកន្លងមកតាមរយៈសេចក្តីជូនដំណឹងលេខ ០០៥១ ព.ណ.ចបព ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ ស្តីពី ការលើកលែងការពិន័យចំពោះក្រុមហ៊ុនខកខានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ឱ្យមកបំពេញកាតព្វកិច្ចរហូតដល់ថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦។ ដូច្នេះ ក្រសួងពាណិជ្ជកម្ម សូមជូនដំណឹងដល់ម្ចាស់ក្រុមហ៊ុន ឬអ្នកគ្រប់គ្រងក្រុមហ៊ុនទាំងអស់ឱ្យបានជ្រាបអំពី**ការបន្តលើកលែងការពិន័យចំពោះក្រុមហ៊ុនខកខានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំនីមួយៗសម្រាប់រយៈពេល ៦ ខែបន្ថែមទៀត** ដោយត្រូវបំពេញលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

១. ត្រូវបង់ប្រាក់ពិន័យមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំសម្រាប់រយៈពេល ១ ឆ្នាំចុងក្រោយ និងបង់កម្រៃសេវាតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ តាមចំនួនឆ្នាំដែលមិនបានបង់ជាក់ស្តែង ក្នុងអំឡុងពេល ៦ ខែចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ

២. ត្រូវចូលរួមក្នុងការត្រួតពិនិត្យសាវតាររូបវន្តបុគ្គលរបស់ម្ចាស់ហ៊ុន (Background Check) ដើម្បីរួមចំណែកក្នុងការពង្រឹងការងារប្រយុទ្ធប្រឆាំងការលាងសម្អាតប្រាក់។

ក្នុងករណីក្រុមហ៊ុនមិនបានអនុវត្តតាមលក្ខខណ្ឌ និងកាលបរិច្ឆេទកំណត់ខាងលើ នឹងត្រូវចាត់ទុកជាក្រុមហ៊ុនអកម្ម (Inactive Company) ដែលអាចប៉ះពាល់ដល់សិទ្ធិ និងស្ថានភាពរបស់ក្រុមហ៊ុនស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងពាណិជ្ជកម្ម សូមអំពាវនាវដល់ក្រុមហ៊ុនទាំងអស់ ត្រូវបំពេញកាតព្វកិច្ចផ្លូវច្បាប់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ឱ្យបានទាន់ពេលវេលាតាមការកំណត់។ ក្នុងករណីមានបញ្ហាបច្ចេកទេសក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំក្នុងប្រព័ន្ធចុះបញ្ជី សូមទំនាក់ទំនងមកក្រុមការងារចំពោះកិច្ចតាមរយៈប្រព័ន្ធទូរសព្ទសាធារណៈក្រសួងពាណិជ្ជកម្ម **លេខ ១២៦៦ (សូមចុចលេខ ២ សម្រាប់ការងារចុះបញ្ជីពាណិជ្ជកម្ម)** ដើម្បីក្រុមការងារជួយដោះស្រាយជូនបានទាន់ពេលវេលា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់ក្រុមហ៊ុន ឬអ្នកគ្រប់គ្រងក្រុមហ៊ុនទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្ត ដើម្បីទទួលបានអត្ថប្រយោជន៍ពីការលើកលែងការពិន័យ និងអនុលោមតាមមាត្រា៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម៕

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

**ស្កេនដើម្បីទាញយក ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម**

**ប្រព័ន្ធទូរសព្ទសាធារណៈ ក្រសួងពាណិជ្ជកម្ម**

1266

១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ contact@moc.gov.kh